**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៣៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងមុខតំណែងមន្ត្រីរាជការចំនួន ១១រូប ជា **អភិបាលក្រុង** និង**អភិបាលស្រុក** នៃខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :

១- លោក **ចាន់ សុខុម** បានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៤ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជា**អភិបាល ក្រុងតាខ្មៅ**

២- លោក **ហេង ឆៀម** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ១១ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជា**អភិបាល ស្រុកក្បៀនស្វាយ**

៣- លោក **សាមុត ធឿន** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៧ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជា**អភិបាល ស្រុកអង្គស្នួល**

៤- លោក **ទឹម ចន្ទគិរី** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជា**អភិបាល ស្រុកស្អាង**

៥- លោក **ខាច់ សុវណ្ណ** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងបរិស្ថាន ជា**អភិបាល ស្រុកលើកដែក**

៦- លោក **គុន ស៊ីវមី** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៩ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលក្រសួងធនធានទឹក និងឧតុនិយម ជា**អភិបាល ស្រុកពញាឮ**

៧- លោក **ចយ សុបិន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ១០ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជា**អភិបាល ស្រុកកណ្តាលស្ទឹង**

៨- លោក **អ៊ិន យុន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៩ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជា**អភិបាល ស្រុកកោះធំ**

៩- លោក **ម៉ុន ផេង** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៩ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជា**អភិបាល ស្រុកល្វាឯម**

១០- លោក **តាំង ម៉េងលាន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៩ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជា**អភិបាល ស្រុកមុខកំពូល**

១១- លោក **គង់ សោភ័ណ្ឌ** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៩ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជា**អភិបាល ស្រុកខ្សាច់កណ្តាល** ។

**មាត្រា ២.-**

ក្នុងរយៈពេលមកបំពេញភារកិច្ចក្នុងមុខតំណែងថ្មីខាងលើ លោក **ខាច់ សុវណ្ណ** និងលោក **គុន ស៊ីវមី** ត្រូវដាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
  *(ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*